ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**កិច្ចព្រមព្រៀង រវាង**

# នាយកតំណាងក្រុមហ៊ុន អិមជេ ប៊ែក(ខេមបូឌា) ខូអិលធីឌី

## និងតំណាងកម្មករប្រតិភូបុគ្គលិកនិងប្រធានក្រុមប្រចាំក្រុមហ៊ុន

នៅថ្ងៃទី១០ខែតុលាឆ្នាំ២០២០វេលាម៉ោង២និង១០នាទីរសៀលនៅក្នុងរោងចក្រអិមជេប៊ែក(ខេមបូឌា)ខូអិលធីឌីមានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុននិងតំណាងកម្មករនិយោជិត។

នៅក្នុងអង្គប្រជុំនេះនាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់ស្តីពីស្ថានភាពបច្ចុប្បន្ននៃក្រុមហ៊ុនដែលខ្វះវត្ថុធាតុដើមពីប្រទេសផ្គត់ផ្គង់វត្ថុធាតុដើមដោយសារប្រទេសនោះរងផលប៉ះពាល់ជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរកូវីដ-១៩(Covid-19)។ហេតុដូចនេះក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន៧៩នាក់(ស្រី៥៨នាក់)ក្នុងចំណោមកម្មករនិយោជិតសរុប១៩៩នាក់(ស្រី៩២នាក់)ក្នុងរយៈពេល៦០ថ្ងៃដោយគិតចាប់ពីថ្ងៃ១៤ខែតុលាឆ្នាំ២០២០។ដោយក្នុងកំឡុងរយៈពេលព្យួរការងារនេះកម្មករនិយោជិតបានឯកភាពទទួលការផ្តល់ជូននូវប្រាក់ឈ្នួល៣០ដុល្លាសហរដ្ឋអាមេរិច។

**ប្រាក់ឧបត្ថមក្នុងអំឡុងពេលព្យួរការងារនេះនិងបើកជូនបងប្អូនកម្មករនៅថ្ងៃទី១០ខែបន្ទាប់។**

អង្គប្រជុំបានចប់វេលាម៉ោង៣និង៣០នាទីរសៀលនាថ្ងៃខែដដែលប្រកបដោយបរិយាកាសរីករាយនិងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន។

ថ្ងៃសៅរ៍ ទី៨រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ២៥៦៤

ព្រះសីហនុ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០

ភាគីតំណាងក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន អិម ជេ ប៊ែក ខេមបូឌា ខ.ក M.J BAGS (CAMBODIA) Co.,Ltd. KINGDOM OF CAMBODIA

王庆春

Wang qing Chun

ភាគីតំណាងកម្មករនិយោជិត